# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤១១ អក.តក-៩៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបចក**

**លោក ប្រធានតុលាការខេត្តតាកែវ**

**លោក ព្រះរាជអជ្ញាអមតុលាការខេត្តតាកែវ**

**សូមជ្រាប។**

**កម្មវត្ថុ:** ករណីពិរុទ្ធជនឃុំខ្លួនហួសថេរៈវេលាកំណត់ នៃច្បាប់ចំនួន៤នាក់ ។
**យោង:** របាយការណ៍ត្រួតពិនិត្យពន្ធនាគារលេខ ៦៦២ អក-៩៦ ចុះថ្ងៃទី៣០-១០-៩៦ របស់ព្រះរាជអាជ្ញអមតុលាការខេត្តតាកែវ ។

ខ្ញុំសូមជម្រាបលោកថា ករណីពិរុទ្ធជនឃុំខ្លួនហួសថេរៈវេលាកំណត់ នៃច្បាប់នេះក្រសួងបានធ្វើលិខិតលេខ ១៣៦០ ពគ-៩៥ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ជូនមកលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញអមតុលាការខេត្តតាកែវ រួចហើយប៉ុន្តែមកដល់ពេលនេះក្រសួងនៅតែឃើញមានការឃុំខ្លួនពិរុទ្ធជនហួសៈថេរៈវេលានៃច្បាប់ជាបន្តបន្ទាប់ទៀតដដែល ។

ហេតុនេះ សូមលោកមានវិធានការលើកយកសំណុំរឿងទាំង៤នេះ មកចាត់ការដាក់ជំនុំជម្រះឲ្យបានឆាប់រហ័សជាទីបំផុត ។ ក្នុងករណីនៅតែមានពិរុទ្ធជនឃុំខ្លួនហួសថេរៈវេលាកំណត់នៃច្បាប់ទៀត ក្រសួងនិងអោយលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមខេត្តតាកែវ ទទួលខុសត្រូវអំពីផ្លូវច្បាប់ ។

ម្យ៉ាងទៀត ចំពោះបន្ទប់ដាក់ពិរុទ្ធជនបើមានលក្ខណៈចង្អៀត សូមលោកព្រះរាជអាជ្ញាសហការជាមួយប្រធានមន្ទីរឃុំឃាំង ដើម្បីបើកបន្ទប់បិទជិតខាងលើ ជួសជុលសម្រាប់ប្រើប្រាស់ដាក់ពិរុទ្ធជនធម្មតាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**